ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៩៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការធ្វើអនុបយោគដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ សម្រាប់សម្បទានដីសង្គមកិច្ច រៀបចំបង្កើតជាភូមិសែនជ័យ ស្ថិតនៅក្នុងឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៩/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួល អគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :**

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីព្រៃសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀតនូវដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ មានទំហំសរុប ៤៦១៥ ហិកតា ស្ថិតក្នុងឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដូចមានផែនទីជូនភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ហើយកំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកាដូចខាងក្រោម :

A ( ៤៧៨០០៤, ១៥៧៩៣១៣ ) B ( ៤៧៨០០០, ១៥៨១៤០០ ) C ( ៤៧៧០០០, ១៥៨១៤០០ )
D ( ៤៧៧០០២, ១៥៧៩៣១០ ) E ( ៤៧៥១១៣, ១៥៧៩៣១៤ ) F ( ៤៧៥០៩៩, ១៥៨០០០០ )
G ( ៤៧៥៥០០, ១៥៨០០០០ ) H ( ៤៧៥៥០០, ១៥៨១០០០ ) I ( ៤៧៥០៧៨, ១៥៨១០០០ )
J ( ៤៧៤៩២០, ១៥៨៨៦២៧ ) K ( ៤៧៧៩២០, ១៥៨៨៦២៧ ) L ( ៤៧៩៩២០, ១៥៨៨៦២៧ )
M ( ៤៧៩៩៧៣, ១៥៨៦០០៧ ) N ( ៤៧៩០០២, ១៥៨៦០១៥ ) O ( ៤៧៩០០៨, ១៥៨៥០០០ )
P ( ៤៧៩៩៩០, ១៥៨៥០០៣ ) Q ( ៤៨០០៣២, ១៥៨៣០០០ ) R ( ៤៧៩០០០, ១៥៨៣០០០ )
S ( ៤៧៩០០០, ១៥៨២០០០ ) T ( ៤៨០០៥៧, ១៥៨១៩៩៨ ) U ( ៤៨០១១៣, ១៥៧៩៣១៤ )
V ( ៤៧៨៥០០, ១៥៨៣០០០ ) W ( ៤៧៧៥០០, ១៥៨៣០០០ ) X ( ៤៧៧៥០០, ១៥៨៤០០០ )
Y ( ៤៧៨៥០០, ១៥៨៤០០០ ) ។

**មាត្រា ២ :**

ត្រូវបានរំសាយផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ដូចមានក្នុងមាត្រា ១ នៃអនុក្រឹត្យនេះចេញពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ។

**មាត្រា ៣ :**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ បួនពាន់ប្រាំមួយរយដប់ប្រាំ ហិកតា (៤៦១៥ ហិកតា) ដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

**មាត្រា ៤ :**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋ ទំហំ បួនពាន់ប្រាំមួយរយដប់ប្រាំ ហិកតា(៤៦១៥ ហិកតា) ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាអាជ្ញាធរកាន់កាប់ដីរដ្ឋ ដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋ សម្រាប់បែងចែកជាសម្បទានដីសង្គមកិច្ចជូនគ្រួសារយោធិន និង នគរបាលរៀបចំបង្កើតជាភូមិសែនជ័យស្ថិតក្នុងឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ស្របតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល និងតម្រូវការជាក់ស្ដែង ។

**មាត្រា ៥ :**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង អភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៩៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០០៩
ស្តីពីការធ្វើអនុបយោគដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ សម្រាប់សម្បទានដីសង្គមកិច្ច រៀបចំបង្កើត
ជាភូមិសែនជ័យ ស្ថិតនៅក្នុងឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ




សញ្ញាសំគាល់
- ចំណុចគោល
- ទីតាំងវះសេនាតូចលេខ ៣៧២
- ព្រំប្រទល់សម្បទានដីសង្គមកិច្ច( ពុំរាប់បញ្ចូលផ្ទៃដីទីតាំងវះសេនាតូចលេខ ៣៧២)
- ស្ទឹង អូរ
- ផ្លូវ
- ខ្សែរបោះកំពស់

និយាមការទីតាំង

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| A | 478004 | 1579313 | I | 475078 | 1581000 | Q | 480032 | 1583000 |
| B | 478000 | 1581400 | J | 474920 | 1588627 | R | 479000 | 1583000 |
| C | 477000 | 1581400 | K | 477920 | 1588627 | S | 479000 | 1582000 |
| D | 477002 | 1579310 | L | 479920 | 1588627 | T | 480057 | 1581998 |
| E | 475113 | 1579314 | M | 479973 | 1586007 | U | 480113 | 1579314 |
| F | 475099 | 1580000 | N | 479002 | 1586015 | V | 478500 | 1583000 |
| G | 475500 | 1580000 | O | 479008 | 1585000 | W | 477500 | 1583000 |
| H | 475500 | 1581000 | P | 479990 | 1585003 | X | 477500 | 1584000 |
| | | | | | | Y | 478500 | 1584000 |

COORDINATE SYSTEM
Projection :UTM
Zone : 48 N
Horizontal Datum : Indian 1960
Spheroid : Everest

N W E S

មាត្រដ្ឋាន ១: ១០០ ០០០
១ ០ ១គ.ម